MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# សហគមន៍មានសុវត្ថិភាព ៦

adpc

មិថុនា ២០០៩

# ការយកចិត្តទុកដាក់ចំពោះអ្នកដែលងាយរងគ្រោះបំផុត

## *ការបញ្ជ្រាបបញ្ហាយេនឌ័រនៅក្នុងកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នៅកម្ពុជា*

### ពត៌មានសង្ខេប

សកម្មភាពជាច្រើននៅក្នុងករណីសិក្សានេះគឺបង្កើត និងអនុវត្តកម្មវិធីមួយដែលឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាផ្សេងៗរបស់ស្ត្រីដែលជាអ្នកដឹកនាំគ្រួសារ។ នៅលើកទីមួយការសិក្សាស្រាវជ្រាវបានធ្វើឡើងដើម្បីកំណត់បញ្ហាទូទៅដែលស្ត្រីជាអ្នកដឹកនាំគ្រួសារបានប្រឈម និង បញ្ហាជាក់លាក់មួយចំនួនទៀតរបស់ពួកគាត់ ដែលគាត់បានជួបប្រទះនៅក្នុងពេលមានគ្រោះទឹកជំនន់។ លទ្ធផលនៃការចុះសិក្សាស្រាវជ្រាវទាំងនោះបានលើកយកមកពិភាក្សានៅក្នុងសិក្ខាសាលាចំនួនពីរលើកនាពេលចុងក្រោយនេះ ដោយមានការចូលរួមពីគណ:កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្តស្រុកនិងឃុំដូចជាការអញ្ជើញចូលរួមពីមន្ទីរកិច្ចការនារីខេត្ត។ សិក្ខាសាលាបានផ្តល់អនុសាសន៍ទៅលើការកសាងសមត្ថភាព និងការចែករំលែកចំណេះដឹងអំពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ដោយស្ត្រីជាមេគ្រួសារនិង ជនបង្គោលស្ត្រី និង កុមារថ្នាក់ឃុំ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានសហការជួយសម្របសម្រួលនូវការចូលរួមរបស់ស្ត្រីនិងកុមារនៅក្នុងសកម្មភាពបីនៃកម្មវិធីត្រៀមបង្ការនិងកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់។ នៅទីបញ្ចប់នៃសិក្ខាសាលានោះការសម្រេចចុងក្រោយយុទ្ធនាការផ្សព្វផ្សាយជាសាធារណ:បានប្រព្រឹត្តទៅនៅក្នុងភូមិគោលដៅមួយចំនួន ដែលមានស្ត្រីជាមេគ្រួសារ។

### ខ្លឹមសាររឿង

- យេនឌ័រក្នុងកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់សម្រាប់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ ២
- ការប្រមូលអំពីដំណោះស្រាយបញ្ហាការដឹកនាំការងាររបស់ស្ត្រី ចំពោះស្ត្រី ៣
- ជំហានបន្ទាប់ ៣




*សិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការកំណត់សេចក្តីត្រូវការទាក់ទងនឹងគ្រោះទឹកជំនន់សំរាប់ស្ត្រីជាមេគ្រួសារនៅក្នុងខេត្តព្រៃវែង*

### សេចក្តីផ្តើម

តាមរយ:ការប៉ាន់ប្រមាណ បានឱ្យឃើញថានៅក្នុងប្រទេសកម្ពុជាយើងមានគ្រួសារចំនួន២៩,២ % ត្រូវបានដឹកនាំដោយស្ត្រី។ តួលេខភាគរយនៃស្ត្រីមេគ្រួសារនេះមានកម្រិតខ្ពស់នៅតាមតំបន់ជនបទ (២៩,៣%) ច្រើនជាងនៅតាមតំបន់ទីក្រុង (២៨,៤%)។ គ្រួសារមួយចំនួនជាស្ត្រីមេម៉ាយ ដែលនៅសល់ពីសង្គ្រាមស៊ីវិលជាច្រើនទសវត្ស។ អ្នកខ្លះទៀតបានលែងលះគ្នា ឬត្រូវបានប្តីបោះបង់ចោល ។

ទោះបីជាគ្រួសារដឹកនាំដោយស្ត្រីទាំងអស់មិនត្រូវបានគេផ្តល់តួនាទីណាមួយក្តី ក៏គ្រួសារស្ត្រីក្រីក្រមួយចំនួនមានកម្មសិទ្ធិកាន់កាប់ដីធ្លីតូចៗជាច្រើន ដែលងាយនឹងបាត់បង់បំផុតដោយសារវិបត្តិសេដ្ឋកិច្ចគ្រួសារ និងមានអត្រាការងារពលកម្មកុមារខ្ពស់ជាងគ្រួសារទាំងឡាយណា ដែលមានបុរសជាដឹកនាំ។ ស្ត្រីទាំងនោះទទួលបានផលប្រយោជន៍តិចតួចពីការអភិវឌ្ឍន៍ ឬការអន្តរាគមន៍ជំនួយមនុស្សធម៌នានា ដោយសារតែ កត្តាពីរយ៉ាងគឺ១-ទំនាក់ទំនងបែបប្រពៃណីជាមួយនឹងឋានានុក្រមគ្រប់គ្រង ដែលផ្ទុយទៅវិញឋានានុក្រមទាំងនោះ សុទ្ធតែត្រូវបុរសកាន់កាប់ ទាំងអស់។២-ប្រសិនបើមានការពិភាក្សាតាមសហគមន៍ បុរសដែលជាអ្នកធ្វើការសម្រេចចិត្តនៅក្នុងសហគមន៍នោះ តែងតែមិនឱ្យស្ត្រីចូលរួមបានយ៉ាងសកម្មឡើយនៅក្នុងកិច្ចពិភាក្សា។ ឧបសគ្គទាំងនេះហើយដែលបានបង្វែរជំនួយ ក៏ដូចជាព័ត៌មានសំខាន់ៗទាក់ទងនឹងការអភិវឌ្ឍន៍ និងសកម្មភាពមនុស្សធម៌ដទៃទៀតពីគ្រួសារទាំងឡាយណាដែលបានដឹកនាំដោយស្ត្រី។

នៅក្នុងប្រទេសកម្ពុជា ខេត្តកណ្តាល និងខេត្តព្រៃវែង គឺជាខេត្តដែលអនុវត្តគម្រោងកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ជាច្រើន ដែលរៀបចំដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន សហការជាមួយនឹងអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយតាមមូលដ្ឋានក្នុងទិសដៅកាត់បន្ថយគ្រោះភ័យនានាដែល

បណ្តាលមកពីទឹកជំនន់ទន្លេមេគង្គប្រចាំឆ្នាំ។ ជាទូទៅអាជ្ញាធរទាំងនោះត្រូវបានកំណត់នៅក្នុងសហគមន៍មូលដ្ឋាន នោះហើយពួកគាត់មួយចំនួនជាក្រុមនៃសហគមន៍ដែលចាត់ទុកជាក្រុមដែលងាយរងគ្រោះថ្នាក់បំផុតដូចជា: មនុស្សចាស់ ជនជាតិភាគតិច កុមារ និងស្ត្រី។

នៅក្នុងប្រទេសកម្ពុជា ក្រសួងកិច្ចការនារី (MoWA) គឺជាស្ថាប័នសំខាន់មួយដែលទទួលខុសត្រូវក្នុងការពង្រឹងគោលនយោបាយសម្រាប់ភាពរីកចម្រើនរបស់ស្ត្រី។ប៉ុន្តែវាត្រូវបានគេមើលឃើញថា ការអនុវត្តកម្មវិធីយេនឌ័រនៅក្នុងប្រទេសកម្ពុជា មានការលំបាកខ្លាំងណាស់ដោយសារ សមត្ថភាពមូលដ្ឋានដែលមាននោះនៅមានកម្រិត ពិសេសនៅកម្រិតសហគមន៍។ ដូចនេះហើយ ជម្រើសដែលល្អបំផុតហើយសំខាន់ក្នុងកម្មវិធីនេះ គឺការពង្រឹងសមត្ថភាពដល់រចនាសម្ព័ន្ធក្រសួងកិច្ចការនារីនៅថ្នាក់មូលដ្ឋាន ជាពិសេសអ្នកទទួលបន្ទុកស្ត្រី និងកុមារនៅថ្នាក់ឃុំ ដែលពួកគាត់ជាផ្នែកមួយនៃសហគមន៍ដែលមានស្រាប់ ឱ្យក្លាយជាសកម្មជនឆ្នើមនៃបំលាស់ប្តូរ និងជាអ្នកជួយពង្រីកចំណេះដឹងដល់សហគមន៍បានទូលំទូលាយ ទៅតាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋានរបស់គាត់ ។

> "គ្រួសារដែលមានស្ត្រីជាអ្នកដឹកនាំត្រូវបានគេរើសអើង និងត្រូវដាក់ឱ្យនៅឯកោនៅក្នុងសហគមន៍ ហើយត្រូវតែពឹងផ្អែកលើសមាជិក គ្រួសាររបស់ពួកគេក្នុងការជួយជ្រោមជ្រែងនៅពេលមានវិបត្តិ ពីព្រោះស្ត្រីទាំងនោះមានលទ្ធភាពនៅមានកម្រិតក្នុងការស្តារឡើងវិញ ដូចជាទាំងការទទួលបានជំនួយសេដ្ឋកិច្ច និងជំនួយមនុស្សធម៌" ។ ទាក់ទិនទៅនឹងគោលជំហរផ្នែកសង្គម ស្ត្រីទាំងនោះគឺជាអ្នកដែល មានតួនាទីទាប ហើយមានសិទ្ធិតិចតួចណាស់នៅក្នុងជីវភាពរស់នៅរបស់ពួកគេ។"
>
> លោកស្រី ហួយ សុជីវណ្ណី ប្រធានអង្គការបំលាស់ប្តូរជាវិជ្ជមានសម្រាប់កម្ពុជា (PCC)

នៅក្នុងឆ្នាំទី២ នៃកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) ដែលនៅក្រោមផ្នែកទី៤ នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់របស់គណៈកម្មការទន្លេមេគង្គ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក (PCDM និង DCDM) នៃតំបន់គោលដៅគឺស្រុកល្វាឯម និងស្រុកលើកដែកនៃខេត្តកណ្តាល និងស្រុកពាមជរ៍ និងស្រុកស៊ីធរកណ្តាលនៃខេត្តព្រៃវែងបានធ្វើការកំណត់ និងបង្កើតសកម្មភាពផ្តោតលើបញ្ហាយេនឌ័រឱ្យទៅជាផ្នែកមួយនៃគម្រោងអាទិភាពតូចៗ ដែលស្ថិតនៅក្រោមការអនុវត្តនៃកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ខេត្ត និងស្រុក។ មន្ទីរ និងការិយាល័យកិច្ចការនារីខេត្ត ស្រុក (DWA) នៅក្នុងតំបន់គោលដៅបានដឹកនាំក្រុមគោលដៅធំៗ ចំនួនពីរក្រុម ដែលកំណត់ថាជាអ្នកទទួលផល គឺជនបង្គោលស្ត្រី និងកុមារនៅថ្នាក់ឃុំ ហើយនិងគ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ។



សិក្ខាកាមបានឆ្លៀតពេលថតរូបអនុស្សាវរីយ៍បន្ទាប់ពីកំណត់បញ្ហានិងសេចក្តីត្រូវការក្នុងកំឡុងពេលទឹកជំនន់របស់ស្ត្រីមេគ្រួសារ

## យេនឌ័រក្នុងកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់សម្រាប់គ្រួសារដែលមានស្ត្រីជាមេគ្រួសារ

រចនាសម្ព័ន្ធក្រសួងកិច្ចការនារីត្រូវបានតំណាងដោយ មន្ទីរកិច្ចការនារីនៅថ្នាក់ខេត្ត និង ដោយការិយាល័យកិច្ចការនារីនៅថ្នាក់ស្រុក និងថ្នាក់ឃុំដោយអ្នកទទួលបន្ទុកស្ត្រី និងកុមារឃុំ។ អ្នកទទួលបន្ទុកស្ត្រី និងកុមារឃុំត្រូវទទួលខុសត្រូវខ្ពស់ក្នុងការប្រតិបត្តិអាណត្តិនៃក្រសួងកិច្ចការនារី នៅថ្នាក់ឃុំ ដោយផ្តោតទៅលើវិស័យអាទិភាពទាំង០៤គឺ ការអប់រំ សុខភាព ការលើកកម្ពស់ស្ត្រីនៅក្នុងវិស័យសេដ្ឋកិច្ចនិងការការពារស្ត្រីនៅក្នុងផ្នែកច្បាប់ (អំពើហឹង្សាក្នុងគ្រួសារ)។ ចំណែកឯក្រសួងកិច្ចការនារីគឺជាសមាជិកមួយនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM-កម្ពុជា) និងជាស្ថាប័នតំណាងនៃក្រសួងកិច្ចការនារីនៅថ្នាក់ខេត្ត ស្រុក និងថ្នាក់ឃុំ ក៏ជាសមាជិកនៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៃកម្រិតនីមួយៗរបស់ពួកគាត់ផងដែរ។




*អ្នកតំណាងជាផ្លូវការនៅគ្រប់កំរិតនៃការិយាល័យកិច្ចការនារី*

## ការរៀបចំកម្មវិធីដែលសមស្រប: ការកំណត់ពីតម្រូវការរបស់ស្ត្រីដែលជាមេគ្រួសារ

ការសិក្សាមួយបានរៀបចំឡើងដោយកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) ដើម្បីរៀបចំកម្មវិធីដែលផ្តោតលើយេនឌ័រសម្រាប់ផ្តល់អត្ថប្រយោជន៍ដល់ស្ត្រីដែលជាមេគ្រួសារក្រីក្រនានា ដែលកំពុងរស់នៅក្នុងតំបន់ងាយរងគ្រោះនឹងគ្រោះទឹកជំនន់។ ការសិក្សាដែលបានរៀបចំដោយទីប្រឹក្សាជនជាតិខ្មែរនេះបានអនុវត្តដោយចែកចេញជាពីរដំណាក់កាលគឺ:

- ជំហានទី ១: ការរៀបចំការស្រាវជ្រាវនៅលើតុ ដោយការចងក្រងទិន្នន័យដែលទទួលបានពីប្រភពដើម ទៅលើបញ្ហានានាដែលគ្រួសារមានស្ត្រីជាមេគ្រួសារតែងតែបានជួបប្រទះនៅក្នុងរដូវទឹកជំនន់។
- ជំហានទី ២: ការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងអ្នកទទួលបន្ទុកស្ត្រី និងកុមារឃុំ ដែលបានជ្រើសតាំងហើយនៅក្នុងឃុំគោលដៅ មន្ទីរ និង ការិយាល័យកិច្ចការនារីខេត្ត និងស្រុក និងជនបង្គោលគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុកនៅក្នុងខេត្តព្រៃវែង និងខេត្តកណ្តាល។ នៅក្នុងកិច្ចប្រជុំនោះលទ្ធផលនៃការស្រាវជ្រាវនៅលើតុត្រូវបានចែកជូនទៅដល់សិក្ខាកាមដើម្បីទទួលបានការបញ្ចេញបន្ថែមការកែតម្រូវ និងសំណូមពរនានាដោយផ្អែកលើបទពិសោធន៍ជាក់ស្តែងក្នុងការរស់នៅរបស់សិក្ខាកាមទាំងអស់នោះ។ ការសិក្សាស្រាវជ្រាវនោះបានបញ្ចប់ និងសរុបសេចក្តីនៅដើមខែ កញ្ញា ឆ្នាំ ២០០៦ ព្រមទាំងបានចែកជូនទៅអ្នកចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ដ៏ធំនៅថ្នាក់ខេត្ត។ នៅក្នុងខេត្តព្រៃវែង សិក្ខាសាលានេះមានសិក្ខាកាមចូលរួមចំនួន ៣៤នាក់ ដែលមានអ្នកតំណាងចំនួន ១៤នាក់មកពីថ្នាក់ខេត្ត និងស្រុក[៩] ហើយអ្នកទទួលបន្ទុកស្ត្រី និងកុមារឃុំចំនួន២០នាក់មកពីថ្នាក់ឃុំ។

[៩] មកពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក (PCDM & DCDM) ព្រមទាំងមកពីមន្ទីរ/ការិយាល័យកិច្ចការនារីខេត្ត និងស្រុក

**បញ្ហាជាទូទៅនានា ដែលស្ត្រីជាមេគ្រួសារតែងតែប្រឈម**

- ការបាត់បង់ដីធ្លី ដោយការលក់ ឬបោះបង់ចោលដោយសារវាផ្តល់ទិន្នផលកសិកម្មតិចតួច ដែលជាហេតុបណ្តាលឱ្យពួកគាត់ជំពាក់បំណុលគេ កាន់តែច្រើនឡើង
- ចំនួនសមាជិកគ្រួសារជាបុរសជាច្រើនធ្វើចំណាកស្រុក ដែលធ្វើឱ្យពួកគាត់គ្មានអ្នកជួយរំលែកបន្ទុកការងារនៅពេលគ្រោះទឹកជំនន់ និងគ្រោះ រាំងស្ងួត ហើយទិន្នផលកសិកម្មក៏បានតិចតួច ដូចនេះពួកគេត្រូវចេញទៅរកការងារធ្វើនៅកន្លែងផ្សេងៗ
- ការរកការងារធ្វើច្រើនប្រភេទដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃធ្វើឱ្យបន្ទុកការងារកាន់តែធ្ងន់ ហើយកូនៗមិនបានទៅសាលា (កូនៗត្រូវឈប់រៀន ដើម្បីជួយការងារម្តាយ ។ បញ្ហាទាំងនោះប៉ះពាល់លើកុមារីច្រើនជាងកុមារា ។
- គ្រួសារមានសមាជិកច្រើន គឺងាយនឹងរងគ្រោះដល់សុខភាព ខ្វះចំណីអាហារ និងគ្មានអនាម័យ
- មិនទទួលបាននូវសេវាឥណទាន (ជាផ្លូវការ និង មិនផ្លូវការ) គ្រប់គ្រាន់-ការរើសអើង: គ្មានទ្រព្យសម្បត្តិគ្រប់គ្រាន់សម្រាប់ដាក់តំកល់ក្នុងការខ្ចីលុយ ។ នៅកន្លែងខ្លះ គឺមានក្រុមជួយខ្លួនឯង (SHG) ហើយពួកគេផ្តល់ប្រាក់កំចីដល់មេគ្រួសារជាស្ត្រី ប៉ុន្តែមិនមែនពួកគេទាំងអស់គ្នា បានទទួលកំចីនោះឡើយ ។

**បញ្ហាជាក់លាក់ ដែលស្ត្រីជាមេគ្រួសារតែងតែប្រឈមនៅពេលទឹកជំនន់**

- បន្ទុកការងារប្រចាំថ្ងៃកើនឡើង ដែលត្រូវតែដោះស្រាយដើម្បីធានាឱ្យគ្រួសារមានសុវត្ថិភាព ចំណីអាហារ និងទឹកបរិភោគគ្រប់គ្រាន់ជាដើម
- កម្រិតអប់រំទាប និងខ្វះជំនាញ បានធ្វើឱ្យស្ត្រីក្រីក្រ ដែលជាមេគ្រួសារមិនទទួលបាននូវការងារប្រាកដប្រជាឡើយ
- កង្វះខាតចំណីអាហារ និងទឹកបរិភោគ ដែលធ្វើឱ្យខ្វះខាតអាហារូបត្ថម្ភ ហើយសុខភាពទន់ខ្សោយ គឺដោយសារខ្វះប្រាក់ចំណូល និងជម្រើសការងារនៅមានម្រិត
- បម្លាស់ទីយឺត ដោយសារគ្មានឧបករណ៍ធ្វើដំណើរ មិនមានទូក ឬមធ្យោបាយនានាជារបស់ផ្ទាល់ខ្លួន
- ការទទួលបានសេវាសុខភាពតិចតួចបំផុត (ថែមទាំងធ្វើការងារទាំងឈឺ)
- មិនមានលទ្ធភាពបញ្ជូនកូនទៅរៀនសូត្របន្ត ដូចនេះកូនៗត្រូវតែមិនចូលរៀន ឬឈប់រៀននៅរដូវទឹកជំនន់ ដើម្បីធ្វើការងាររកប្រាក់ចំណូល ដើម្បីផ្គត់ផ្គង់គ្រួសារដែលមានការខ្វះខាតកន្លងមក ។

**មូលហេតុចម្បង ៣យ៉ាងដែលធ្វើឱ្យស្ត្រីជាមេគ្រួសារក្រីក្រជួបនឹងភាពងាយរងគ្រោះថ្នាក់ពីទឹកជំនន់នោះគឺ:**

- ខ្វះខាតធនធាន សម្រាប់ការឆ្លើយតប និងស្តារឡើងវិញលើផលប៉ះពាល់នានានៃហេតុការណ៍ដ៏គ្រោះថ្នាក់
- ខ្វះខាតចំណេះដឹងទាក់ទងនឹងវិធានការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់
- ការទទួលបានព័ត៌មានតិចតួច( មិនដឹងថាទៅទទួលព័ត៌មានពីកន្លែងណា ហើយធ្វើយ៉ាងដូម្តេចដើម្បីស្វែងរកព័ត៌មានឱ្យបានគ្រប់គ្រាន់ និងត្រឹម ត្រូវ) ដែលធ្វើឱ្យពួកគេត្រៀមបង្ការពីមុខសញ្ញាគ្រោះភ័យមិនទាន់ពេលវេលា ។

នៅក្នុងខេត្តកណ្តាលវិញ មានអ្នកតំណាងចំនួន ១៤នាក់មកពីថ្នាក់ខេត្ត និងស្រុក និងអ្នកទទួលបន្ទុកស្ត្រី និងកុមារឃុំចំនួន ២២នាក់មក ពីថ្នាក់ឃុំ បានចូលរួមនៅក្នុងសិក្ខាសាលានេះ ។ នៅក្នុងសិក្ខាសាលាទាំងពីរនេះ ជនបង្គោលរបស់កម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) មកពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយនៃប្រទេស កម្ពុជា (NCDM) និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (PCDM) នៃខេត្តព្រៃវែង និងខេត្តកណ្តាល បានដើរតួនាទីយ៉ាងសំខាន់ជាអ្នកសម្របសម្រួលជាមួយនឹង ទីប្រឹក្សាថ្នាក់ជាតិ និងក្រុមកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ ។

សិក្ខាសាលានេះបានបែងចែកជាពីរវគ្គពិភាក្សាពិសេសគឺ:

- **វគ្គទី១:** ការចាត់អាទិភាពទៅលើសេចក្តីត្រូវការរបស់ស្ត្រីដែលជាមេគ្រួសារ ទាក់ទិនទៅនឹងទិសដៅចំនួនបួនគឺជីវភាពរស់នៅ ជានិរន្តក្នុងអំឡុងពេលទឹកជំនន់ បញ្ហាសុខភាព ការបង្កើនការយល់ដឹង និងការចូលរួមនៅក្នុងដំណើរការសម្រេចចិត្តនៅក្នុងសហគមន៍ ។
- **វគ្គទី២:** ការបង្កើតឱ្យមានការអន្តរាគមន៍នានាដែលអាចអនុវត្តបាននៅថ្នាក់ឃុំដើម្បីបំពេញឱ្យសេចក្តីត្រូវការនានានិងការលំបាករបស់ស្ត្រីជាមេគ្រួសារទាំងនោះ ។



*អ្នកសំរបសំរួលសិក្ខាសាលាបានដឹកនាំក្រុមពិភាក្សាទៅលើលទ្ធភាពអន្តរាគមន៍នៅថ្នាក់ឃុំដើម្បីបំពេញសេចក្តីត្រូវការរបស់ស្ត្រីមេគ្រួសារក្នុងពេលទឹកជំនន់*

អនុសាសន៍រួមមួយដែលទទួលបានពីសិក្ខាសាលាទាំងពីរនេះបានលើកឡើងថា ដើម្បីឱ្យអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំមានសមត្ថភាពដឹកនាំបានលុះត្រាតែត្រូវពង្រឹងសមត្ថភាពរបស់ពួកគេជាមុនសិន នៅក្នុងទិសដៅសំខាន់ៗពីរគឺ: ការពង្រឹងចំណេះដឹងទៅលើការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ពិសេសទៅលើការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់នៅតាមមូលដ្ឋានសហគមន៍ និងការធ្វើផែនការពីរបៀបផ្សព្វផ្សាយព័ត៌មានស្តីពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ទៅដល់ក្រុមគោលដៅ នៃស្ត្រីក្រីក្រដែលជាមេគ្រួសារ ។

- **ការបញ្ចប់សកម្មភាពជាក់លាក់មួយចំនួន**

សំណូមពរ និងអនុសាសន៍ជាច្រើន ដែលបានលើកឡើងនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់នោះត្រូវបានចងក្រង ហើយសកម្មភាពសំខាន់ៗពីរបានត្រូវជ្រើសរើសគឺ:

១-ការកសាងសមត្ថភាពរបស់អ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ

| | |
|---|---|
| • ឃុំព្រែកចង្ក្រាន ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង | ១-ភូមិព្រែកព្នៅ<br>២-ភូមិបាប្រិយ៍<br>៣-ភូមិព្រែកចង្ក្រានក្រោម |
| • ឃុំអង្គរអង្គ ស្រុកពាមជរ៍ ខេត្តព្រៃវែង | ១-ភូមិអង្គរអង្គ<br>២-ភូមិវាលរបងលើ<br>៣-ភូមិវាលរបងក្រោម<br>៤-ភូមិព្រែកត្រែង |
| • ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្ដាល | ១-ភូមិកោះរះក្រោម<br>២-ភូមិកោះរះលើ |
| • ឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្ដាល | ១-ភូមិពាមរាំងលើ<br>២-ភូមិពាមរាំងក្រោម<br>៣-ភូមិថ្មី |

២-ការបង្កើនការយល់ដឹងរបស់ស្ត្រីក្រីក្រដែលជាមេគ្រួសារនិង ស្ត្រីដែលជាអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ អំពីការកាត់បន្ថយគ្រោះភ័យ នៃគ្រោះទឹកជំនន់

សកម្មភាពជាច្រើនត្រូវបានប្រមូលដាក់រួមគ្នាក្នុងទិសដៅធ្វើឱ្យស្ត្រីជាមេគ្រួសារអាចជ្រើសរើសយកវិធានការដ៏ត្រឹមត្រូវនិងងាយៗ ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ពីទឹកជំនន់ ក្នុងការកាត់បន្ថយតម្លៃនៃការស្ដារឡើងវិញ និងការលំបាកដូចនេះវានឹងជួយពួកគេក្នុងការចំណាយពេលវេលាថវិកា និងកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីផ្ដោតតែទៅលើការរកប្រាក់ចំណូលនៅអំឡុងពេល ឬក្រោយពេលរដូវទឹកជំនន់។ តាមរយៈការពិភាក្សាទ្វេភាគីនេះ អាជ្ញាធរថ្នាក់ខេត្ត និងស្រុកជាច្រើនបានគាំទ្រជាឯកច្ឆ័ន្ទចំពោះគោលគំនិតនេះ។

- **ការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក**

សកម្មភាពជាច្រើនបានផ្ដោតទៅលើសមត្ថភាព និង ភាពប៉ិនប្រសប់របស់មូលដ្ឋាន ដើម្បីជាគុណប្រយោជន៍នៃនិរន្តរភាពចំពោះគោលគំនិតនេះ។ កាលពីខែមេសា ឆ្នាំ២០០៧ អង្គការបំលាស់ប្ដូរជាវិជ្ជមានសម្រាប់កម្ពុជា(PCC)[២] ដែលជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ និងមិនស្វែងរកផលចំណេញ បានចូលរួមត្រួតពិនិត្យមើលទៅលើការអនុវត្តសកម្មភាពគម្រោងជាច្រើន។ ទំនួលខុសត្រូវជាចម្បង និងជាក់លាក់ គឺការធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ នៅក្នុងការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ពួកគាត់ដោយសហការជាមួយនឹងមន្ទីរការិយាល័យកិច្ចការនារីខេត្ត និងស្រុកនៅក្នុងកិច្ចការសម្របសម្រួល និងបង្កើតបរិយាកាសប្រសើរមួយសម្រាប់អ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ ដើម្បីគាត់ទទួលរ៉ាប់រងអនុវត្តសកម្មភាពដែលផ្ដោតទៅលើស្ត្រីក្រីក្រដែលជាមេគ្រួសារ។

## ដំណោះស្រាយបញ្ហានានាដែលបានអនុវត្តចំពោះស្ត្រីក្រីក្រដែលជាមេគ្រួសារ

ការសង្កេតជាក់ស្ដែងបានបង្ហាញឱ្យឃើញថាមានផលប៉ះពាល់ ពីការយល់ដឹងតិចតួចអំពីការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនៅក្នុងវិស័យយេនឌ័រ គឺកើតឡើងដោយសារខ្វះការចូលរួមរបស់ស្ត្រីនៅក្នុងការគ្រប់គ្រងគ្រោះភ័យនៅគ្រប់កម្រិតទាំងអស់។ នៅក្នុងខែកក្កដា និងខែ សីហា ឆ្នាំ២០០៧ អង្គការបំលាស់ប្ដូរជាវិជ្ជមានសម្រាប់កម្ពុជាបានសម្របសម្រួលនៅក្នុងសកម្មភាពបង្កើនសមត្ថភាពរបស់អ្នកទទួលបន្ទុកស្ត្រី និងកុមារឃុំ ដោយការបង្កើតសកម្មភាពជាច្រើនទៀតនៅក្នុងគម្រោងសកម្មភាពនៃកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS) ជាពិសេសនៅក្នុងដំណើរការនៃការពិគ្រោះយោបល់ការកែលំអសាឡើងវិញទៅលើកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ និងវគ្គតម្រង់ទិសស្ដីពីការ ត្រៀមបង្ការគ្រោះទឹកជំនន់នៅតាមមូលដ្ឋានសហគមន៍(CBFM) ដែលបានរៀបចំនិងដឹកនាំដំណើរការវគ្គសម្រាប់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (CCDM)។

- **ការចូលរួមក្នុងសិក្ខាសាលាកែសំរួលនិងពិនិត្យឡើងវិញនូវកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ស្រុក**

ការទទួលរ៉ាប់រងអនុវត្តការងារគឺជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យ ហើយសិក្ខាសាលាកែសំរួលនិងឡើងវិញនូវកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ (FPP) ត្រូវបានធ្វើឡើងនៅក្នុងស្រុកគោលដៅទាំង ៤ (១សិក្ខាសាលាក្នុងមួយស្រុក) ដែលស្ថិតនៅក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក(DCDM) គឺស្រុកល្វាឯម និងស្រុកលើកដែកនៃខេត្តកណ្ដាលហើយ និងស្រុកពាមជរ៍ និងស្រុកស៊ីធរកណ្ដាល នៃខេត្តព្រៃវែង។ អ្នកតំណាងជាច្រើនបានមកពីស្ថាប័នពាក់ព័ន្ធជាច្រើនរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (CCDM) ជាពិសេសមេឃុំបានចូលរួមនៅក្នុងសិក្ខាសាលានេះ។ ជាមួយគ្នានេះដែរ អ្នកទទួលបន្ទុកស្ត្រី និង កុមារឃុំចំនួន ១១ នាក់[៣] ក៏បានចូលរួមក្នុងសិក្ខាសាលានេះផងដែរ ដោយមានជំនួយគាំទ្រពីអង្គការបំលាស់ប្ដូរជាវិជ្ជមានសម្រាប់កម្ពុជា (PCC)។

ដោយសារតែសិក្ខាសាលានេះ បានត្រួតពិនិត្យផងដែរលើការរៀបចំផែនការសកម្មភាពថ្នាក់ស្រុកសម្រាប់អនុវត្តកម្មវិធីត្រៀមបង្ការគ្រោះ ទឹកជំនន់ (FPP) នៅមុនពេលរដូវទឹកជំនន់ឆ្នាំ ២០០៧ ទើបការចូលរួមរបស់អ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំនៅក្នុងការពិភាក្សាជាច្រើននោះ បានផ្ដល់ឱកាសល្អមួយសម្រាប់បញ្ចូលបញ្ហារបស់ស្ត្រីក្រីក្រដែលជាមេគ្រួសារទៅក្នុងកម្មវិធីទាំងពីរគឺ កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ថ្នាក់ស្រុក ដែលបានកែសំរួលរួច ក៏ដូចជាផែនការសកម្មភាពឆ្នាំ២០០៧ ដែលបានជំរុញឱ្យដាក់បញ្ចូលទៅក្នុងកម្មវិធីអភិវឌ្ឍន៍ និងវិនិយោគឃុំ/សង្កាត់ (CDP,CIP) នៅក្នុងការរៀបចំផែនការនៅពេលខាងមុខបន្ទាប់។

- **ការចូលរួមរបស់អ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំនៅក្នុងវគ្គបណ្ដុះបណ្ដាលលើការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមមូលដ្ឋានសហគមន៍ (CBFM)**

នៅក្នុងខែសីហា ឆ្នាំ២០០៧ វគ្គតម្រង់ទិសចំនួន៤ ស្ដីពីការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមមូលដ្ឋានសហគមន៍ បានរៀបចំនៅក្នុងស្រុកគោលដៅទាំងបួនរបស់កម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ (FEMS)។ វគ្គបណ្ដុះបណ្ដាលនេះ

[២] អង្គការ PCC ត្រូវបានបង្កើតឡើងដើម្បីជួយពីតំរូវការសិទ្ធិជាមូលដ្ឋានរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា។ អង្គការនេះធ្វើការដើម្បីធានានូវការចូលរួម ផ្នែកគោលការណ៍សិទ្ធិ និង យេនឌ័ររបស់មនុស្ស/ស្ត្រី/កុមារនៅក្នុងគំរោងអភិវឌ្ឍន៍សហគមន៍ និងដើម្បីកសាងសមត្ថភាពអង្គភាពតាមសហគមន៍ និង ក្រុមប្រឹក្សាឃុំក្នុងភាព ជាដៃគូរជាមួយ នឹងអង្គការក្រៅរដ្ឋាភិបាលនានា និងរដ្ឋាភិបាលគ្រប់កំរិត។ PCC គឺជាសមាជិករបស់គណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលស្ដីពីការលុបបំបាត់នូវរាល់ទំរង់ការរើសអើងប្រឆាំងនឹងស្ត្រី (NGO CEDAW)។

[៣] ៤នាក់មកពីស្រុកពាមជរ៍, ២នាក់មកពីស្រុកស៊ីធរកណ្ដាល, ៣នាក់មកពីស្រុកល្វាឯម, ២នាក់មកពីស្រុកលើកដែក។

បានរៀបចំរួមគ្នាដោយអង្គការស្រែខ្មែរ ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយនៅក្នុងប្រទេសកម្ពុជា ដោយសហការជាមួយនឹងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក និងសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ឃុំនៃស្រុកគោលដៅដែលជាអ្នកបានរៀនវគ្គបណ្តុះបណ្តាលរបស់កម្មវិធីពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់នៅក្នុងឆ្នាំ២០០៦។ក្រោមការសម្របសម្រួលរបស់អង្គការបំលាស់ប្តូរជាវិជ្ជមានសម្រាប់កម្ពុជា មានអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំចំនួន១៩នាក់[៤] បានចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។ វគ្គបណ្តុះបណ្តាលនេះមានទិសដៅបង្កើតឱ្យមានគ្រូបណ្តុះបណ្តាល និងគ្រូ សម្របសម្រួលទៅលើវគ្គគ្រប់គ្រងគ្រោះទឹកជំនន់តាមមូលដ្ឋានសហគមន៍នៅថ្នាក់ឃុំ ដែលជាអ្នកផ្ទេរចំណេះដឹងដល់ប្រជាជនជាច្រើននៅក្នុងសហគមន៍ ពិសេសមូលដ្ឋានគ្រឹះនៃទស្សនទានគ្រប់គ្រងគ្រោះទឹកជំនន់តាមមូលដ្ឋានសហគមន៍ និងវិធានការអនុវត្តនៅតាមគ្រួសារ។

- **ការរៀបចំបង្កើតផែនការសកម្មភាពផ្សព្វផ្សាយព័ត៌មាន**

បន្ទាប់ពីវគ្គបណ្តុះបណ្តាលលើការគ្រប់គ្រងគ្រោះទឹកជំនន់តាមមូលដ្ឋានសហគមន៍រួចមក កិច្ចប្រជុំរៀបចំផែនការសកម្មភាពថ្នាក់ស្រុកបានរៀបចំឡើងជាមួយនឹងមន្ទីរកិច្ចការនារីស្រុក និង អ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំដែលត្រូវបានបណ្តុះបណ្តាល ដោយមានវត្តមានពីអ្នកតំណាងថ្នាក់ខេត្តមកពីមន្ទីរកិច្ចការនារី ដែលសរុបមកគឺមានកិច្ចប្រជុំចំនួនបួនត្រូវបានរៀបចំឡើងដោយកិច្ចប្រជុំមួយត្រូវបានរៀបចំនៅក្នុងមួយស្រុក។ កិច្ចប្រជុំនេះ បានសម្រេចជ្រើសរើសភូមិគោលដៅជាច្រើនសម្រាប់រៀបចំសកម្មភាពបង្កើនការយល់ដឹងដល់ស្ត្រីក្រីក្រដែលជាមេគ្រួសារ។

នៅអំឡុងពេលកិច្ចប្រជុំធ្វើបទបង្ហាញថ្នាក់ស្រុក "ផែនការសកម្មភាពផ្សព្វផ្សាយព័ត៌មាន" បានរៀបចំដោយអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ ដើម្បីរៀបចំឱ្យអនុវត្តនៅថ្នាក់ឃុំ។ សកម្មភាពស្នូលនៃផែនការសកម្មភាពផ្សព្វផ្សាយព័ត៌មាននេះគឺកំណត់លើការរៀបចំ និងបង្កើតយុទ្ធនាការបង្កើនការយល់ដឹងដល់ស្ត្រីក្រីក្រដែលជាមេគ្រួសារនៅក្នុងភូមិគោលដៅ។

- **ការអនុវត្តន៍ផែនការសកម្មភាពផ្សព្វផ្សាយព័ត៌មាននៅក្នុងភូមិគោលដៅ**

ការអនុវត្តន៍ផែនការនេះបានចាប់ផ្តើមយ៉ាងឆាប់រហ័ស នៅក្រោយពីសកម្មភាពបង្កើនការយល់ដឹងជាសាធារណៈដំបូងនៅក្នុង ខែសីហា ឆ្នាំ២០០៧ នៅក្នុងភូមិព្រែកព្នៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។ក្នុងនោះដែរ មានស្ត្រីក្រីក្រដែលជាមេគ្រួសារចំនួន ២៥នាក់បានចូលរួមនៅក្នុងសកម្មភាពនេះដែលបានសម្របសម្រួលដោយការិយាល័យកិច្ចការនារីស្រុក និងអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ រួមជាមួយនឹងអង្គការបំលាស់ប្តូរជាវិជ្ជមានសម្រាប់កម្ពុជា។ សកម្មភាពនេះ រួមមានការបញ្ចាំងខ្សែវីដេអូ "ការរស់នៅជាមួយទឹកជំនន់" ដែលផលិតដោយអង្គការ អុកស្វាមកម្ពុជា (OXFAM)។ ខ្សែវីដេអូនេះបានផ្តោតសំខាន់លើប្រការគួរធ្វើ និងមិនគួរធ្វើជាទូទៅនៅតាមគ្រួសារ នៅមុនពេល អំឡុងពេល និងក្រោយពេលទឹកជំនន់ ។

ក្រោយពីការបញ្ចាំងខ្សែវីដេអូរួចភ្លាម ការពិភាក្សាក្រុមបានរៀបចំឡើងដើម្បីរកដំណោះស្រាយលើការលំបាកនានាដែលគ្រួសារស្ត្រីក្រីក្រ តែងតែប្រឈមនៅពេលទឹកជំនន់។ សិក្ខាកាមបានចែកជាបីក្រុមសម្រាប់ពិភាក្សាលើដំណាក់កាលមុនពេល អំឡុងពេល និង ក្រោយពេលទឹកជំនន់។ ដើម្បីទទួលបាននូវគោលគំនិតត្រៀមបង្ការរបស់សិក្ខាកាមគឺត្រូវលើកទឹកចិត្តឱ្យពួកគេសរសេរនូវវិធានការនានាជាច្រើន ដែលនឹងអនុវត្តនៅតាមគ្រួសារនៅក្នុងដំណាក់កាលទាំងបីនៃគ្រោះទឹកជំនន់។ ជាពិសេសក្រោយពីការទស្សនាទៅលើខ្សែវីដេអូ "ការរស់នៅជាមួយទឹកជំនន់" គេឃើញថាសិក្ខាកាមទាំងអស់មានការយល់ដឹងច្រើនអំពីវិធានការទាំង

**សកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់តាមគ្រួសារដែលបានកំណត់ដោយស្ត្រីជាមេគ្រួសារ**

**មុនពេលទឹកជំនន់**

- ប្រើប្រាស់ឈើចងទល់ជុំវិញផ្ទះ ដើម្បីទប់កុំឱ្យផ្ទះរលំដោយសារខ្យល់បក់
- ត្រៀមទូក កាណូត ឬក្បូននានា
- ដាំបន្លែសម្រាប់ជាអាហារ
- ការរក្សាទុកស្បៀងអាហារ (សម្រាប់មនុស្ស និងសត្វ) ថ្នាំពេទ្យ ប្រេង
- ដឹងពីកន្លែងទីទួលសុវត្ថិភាពនៅទីជិតខាងនានា និងផ្លូវទៅកាន់ទីទួលទាំងនោះ
- តាមដានព័ត៌មានអាកាសធាតុ និងកម្រិតទឹកតាមវិទ្យុ និងទូរទស្សន៍
- រក្សាទុកឯកសារសំខាន់នៅកន្លែងមានសុវត្ថិភាព (ដាក់ឱ្យផុតពីទឹក)
- ត្រៀមទឹកស្អាតសម្រាប់បរិភោគ (ដាក់ថ្នាំការពារដង្កូវទឹក)

**អំឡុងពេលទឹកជំនន់**

- មើលថែរក្សាកូន ហើយកុំឱ្យលេងទឹក និងត្រូវជូន និងទៅយកកូនពីសាលារៀនមកវិញ
- ពេលជិះទូក ត្រូវដាក់សំភារៈ សង្គ្រោះជីវិតដូចជា អាវពោង ឬវត្ថុណាដែលអាចអណ្តែតទឹក ដូចជាបំពង់ជ័រកៅស៊ូ និងពោះវៀនកង់ឡានដែលបូមខ្យល់ទុកបាន
- ជម្លៀសទៅកាន់ទីទួលសុវត្ថិភាព ប្រសិនបើចាំបាច់
- យកដើមឬស្សី ឬឈើស្ងួត ឆ្កឹះខ្សែភ្លើងដែលលិចនៅក្នុងទឹក និងត្រូវចៀសចេញពីតំបន់នោះ
- ត្រូវប្រុងប្រយ័ត្នជាមួយនឹងសត្វអសិរពិសនានានៅក្នុងទឹក ដូចជាសត្វពស់ ខ្ទួយ ក្អែប.....
- ត្រូវបរិភោគទឹកដាំឆ្អិន ហើយត្រូវលាងសំអាតប្រដាប់ប្រដាប្រើប្រាស់ នឹងសាប៊ូ ។

**ក្រោយពេលទឹកជំនន់**

- ត្រូវលាងសំអាត និងជួសជុលផ្ទះសម្បែង និងតំបន់ដែលនៅជុំវិញ
- ត្រូវស្វែងរកគ្រាប់ពូជស្រូវ និងដំណាំបន្លែនានា សម្រាប់ដាំឡើងវិញ
- កត់ត្រានូវការខូចខាតនានា
- ប្រើប្រាស់ថ្នាំ សំអាតទឹក និងវិធីសាស្ត្រនានាដើម្បីឱ្យទឹកស្អាតល្អមុននឹងបរិភោគ និងប្រើប្រាស់
- ជួសជុល និងកែតម្រូវហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជាផ្លូវថ្នល់ ស្ពានជាដើម ។

"គ្រួសារដែលមានស្ត្រីជាអ្នកដឹកនាំត្រូវបានគេរើសអើង និងត្រូវដាក់ឱ្យនៅឯកោនៅក្នុងសហគមន៍ ហើយត្រូវតែពឹងផ្អែកលើសមាជិក គ្រួសាររបស់ពួកគេក្នុងការជួយជ្រោមជ្រែងនៅពេលមានវិបត្តិ ពីព្រោះស្ត្រីទាំងនោះមានលទ្ធភាព នៅមានកម្រិតក្នុងការស្តារឡើងវិញ ដូចជាទាំងការទទួលបានជំនួយសេដ្ឋកិច្ច និងជំនួយមនុស្សធម៌"។ ទាក់ទិនទៅនឹងគោលជំហរផ្នែកសង្គមស្ត្រីទាំងនោះ គឺជាអ្នកដែលមានតួនាទីទាប ហើយមានសិទ្ធិតិចតួចណាស់នៅក្នុងជីវភាពរស់នៅរបស់ពួកគេ។"

លោកស្រី ហួយ សុជីវណ្ណី ប្រធានអង្គការបំលាស់ប្តូរជាវិជ្ជមានសម្រាប់កម្ពុជា (PCC)

[៤] ៤នាក់មកពីស្រុកពាមជរ, ២នាក់មកពីស្រុកស៊ីធរកណ្តាល, ៣នាក់មកពីស្រុកល្វាឯម, ២នាក់មកពីស្រុកលើកដែក។

នេះ។ លើសពីនេះទៀត វគ្គបណ្តុះបណ្តាលនេះបានផ្តល់ឱកាសដ៏ល្អមួយ សម្រាប់គ្រួសារក្រីក្រជាស្ត្រីឱ្យចែករំលែក និងបង្ហាញពីបទពិសោធនជីវិតពិតរបស់ពួកគេ ហើយជាឱកាសល្អមួយដែលអាចឱ្យអ្នកទទួលបន្ទុកស្ត្រី និង កុមារឃុំ ចែករំលែកចំណេះដឹង និងជំនាញដែលពួកគេទទួលបានពីការចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលលើការគ្រប់គ្រងគ្រោះទឹកជំនន់នៅតាមមូលដ្ឋានសហគមន៍ (CBFM) និងដំណើរការពិភាក្សាយោបល់លើកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ តាមរយៈការសម្របសម្រួលយ៉ាងសកម្មលើកិច្ចពិភាក្សានានា។

នៅក្នុងសកម្មភាពនេះ ឯកសារអប់រំ (IEC) ដែលបានរៀបចំក្រោមកម្មវិធីពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់បានចែកជូនដល់សិក្ខាកាមទាំងអស់ដូចជាផ្ទាំងរូបភាពពាផ្ទាំង ស្តីអំពី "វិធានការសុវត្ថិភាពគ្រួសារ" និង រូបភាព ២ផ្ទាំងទៀតស្តីពី "ការការពារកុមារកុំឱ្យលង់ទឹក" ជាបន្តបន្ទាប់មកទៀតមានសកម្មភាពដូចគ្នានេះ ដែលរយៈពេលកន្លះថ្ងៃ ត្រូវបានរៀបចំនៅក្នុងភូមិដែលមិនទាន់បានបណ្តុះបណ្តាលនៅចន្លោះ ខែសីហា និងខែកញ្ញា ឆ្នាំ ២០០៧។ សរុបមកស្ត្រីដែលជាមេគ្រួសារចំនួនប្រហែល ៣៨៤នាក់បានទទួលផលប្រយោជន៍យ៉ាងច្រើនពីសកម្មភាពបង្កើនការយល់ដឹងជាសាធារណៈនៅក្នុងភូមិទាំងដប់មួយ។

- **ការផ្សព្វផ្សាយទ្រឹស្តី: ការរៀបចំសៀវភៅស្តើងស្តីពីស្ត្រីក្រីក្រជាមេគ្រួសារ និងទឹកជំនន់**

គេបានយល់ឃើញថា មូលហេតុដែលបណ្តាលឱ្យមានបញ្ហារបស់ស្ត្រីក្រីក្រដែលជាមេគ្រួសារ និងសេចក្តីត្រូវការ/បញ្ហានានាទាក់ទងនឹងទឹកជំនន់ ហើយមិនត្រូវបានដោះស្រាយនៅក្នុងផែនការអភិវឌ្ឍន៍ និងផែនការគ្រប់គ្រងគ្រោះមហន្តរាយគឺដោយសារ:

- **កង្វះខាតទិន្នន័យដែលពាក់ព័ន្ធលើស្ត្រីក្រីក្រជាមេគ្រួសារ:**

ទិន្នន័យនិងព័ត៌មានមិនប្រាកដ និងមិនគ្រប់គ្រាន់ស្តីពីស្ត្រី (ចំនួនស្ត្រីដែលជាមេគ្រួសារ តើមានស្ត្រីចំនួនប៉ុន្មាននាក់មានដីកសិកម្មផ្ទាល់ខ្លួន ។ល។) ដែលបានធ្វើឱ្យអាក់ខានដល់ការរៀបចំយុទ្ធសាស្ត្របានយ៉ាងប្រសិទ្ធភាព ដើម្បីអាចឱ្យយើងគ្រប់គ្រងបានពីចំនួនគ្រួសារក្រីក្ររបស់ស្ត្រីនៅថ្នាក់ក្រោម។

- **កង្វះខាតចំណេះដឹងទាក់ទិននឹងបញ្ហារបស់ស្ត្រីក្រីក្រជាមេគ្រួសារ:**

នៅក្នុងប្រទេសកម្ពុជា ការបញ្ជ្រាបយេនឌ័របានទទួលនូវការរីកចម្រើនជាច្រើន ប៉ុន្តែមិនបានបញ្ចូលទាំងស្រុងទៅក្នុងវិស័យគ្រប់គ្រងគ្រោះមហន្តរាយនោះទេ។ ស្ថាប័នជាច្រើន ដែលមានភាពសកម្មនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ មិនបាន




*សៀវភៅស្តើងរបស់ ADPC ផ្ទុកនូវពត៌មានស្តីពីសេចក្តីត្រូវការរបស់ស្ត្រីមេគ្រួសារក្នុងពេលទឹកជំនន់*

រៀបចំយុទ្ធសាស្ត្របញ្ជ្រាបនេះទេ ហើយក៏មិនបានយល់ឬអនុវត្តឱ្យបានខ្លាំងក្លាក្នុងការដោះស្រាយភាពខុសគ្នានៃយេនឌ័រនៅក្នុងការរៀបចំគោលនយោបាយ និងការអនុវត្ត ដែលធ្វើឱ្យស្ត្រីមិនអាចទទួលបាននូវធនធានសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងប្រទេសឡើយ។ អ្នកខ្លះទៀតមានការយល់ដឹងអំពីទស្សនទានយេនឌ័រថាជា "បញ្ហារបស់ស្ត្រី" នៅក្នុងប្រទេសកម្ពុជា។

ដូចនេះ ដើម្បីបំបាត់នូវបញ្ហានេះ មន្ទីរកិច្ចការនារីខេត្តកណ្តាល និងខេត្តព្រៃវែង ដែលមានជំនួយបច្ចេកទេសពីអង្គការបំលាស់ប្តូរជាវិជ្ជមាន សម្រាប់កម្ពុជា(PCC) បានរៀបចំរួមគ្នានូវកិច្ចប្រជុំបច្ចេកទេសដើម្បីរៀបចំឱ្យបាននូវសៀវភៅស្តើងមួយ។ មាតិកាសំខាន់របស់សៀវភៅនេះ នឹងដោះស្រាយសេចក្តីត្រូវការ និងបញ្ហាសំខាន់ៗរបស់ស្ត្រីជាមេគ្រួសារនៅក្នុងបរិបទផ្តោតលើទឹកជំនន់ និងទំហំនៃការកើតឡើងផ្ទួនៗប្រចាំឆ្នាំរបស់ទឹកជំនន់ទន្លេមេគង្គ ដែលជះឥទ្ធិពលដល់ទិដ្ឋភាពនានារបស់ជីវិតពួកគេយ៉ាងណានោះ។ ឯកសារអប់រំនេះមានគោលបំណងបង្កើនការយល់ដឹងដល់មន្ទីរពាក់ព័ន្ធនានាដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយទៅលើប្រធានបទទឹកជំនន់នេះ។ កិច្ចការនេះបានគូសបញ្ជាក់ឱ្យឃើញផងដែរថាដោយមានការយល់ដឹងច្រើនពីបញ្ហាយេនឌ័រនេះហើយ ទើបមានគុណប្រយោជន៍ច្រើនទៅលើកិច្ចប្រជុំស្តីពីតម្រូវការរបស់ស្ត្រី នៅក្នុងផែនការតាមមន្ទីរ ក៏ដូចជាកម្មវិធីអភិវឌ្ឍន៍ និងកម្មវិធីគ្រោះមហន្តរាយទាំងមូល។

នៅចុងខែកញ្ញា ឆ្នាំ២០០៧ អង្គការបំលាស់ប្តូរជាវិជ្ជមានសម្រាប់កម្ពុជា (PCC) បានរៀបចំកិច្ចប្រជុំថ្នាក់ស្រុកចំនួនបួន ជាមួយនឹងមន្ទីរ-ការិយាល័យកិច្ចការនារីខេត្តនិងស្រុក។ គោលបំណងនៃកិច្ចប្រជុំនេះមានច្រើនគឺដើម្បីបង្ហាញពីបញ្ហារបស់ស្ត្រីដែលបានកំណត់កន្លងមកសម្រាប់បញ្ចូលនៅក្នុងសៀវភៅស្តើង និងដើម្បីស្វែងរកនូវលទ្ធភាពនៃសេវាហិរញ្ញវត្ថុមូលដ្ឋានសម្រាប់បញ្ចូលនៅក្នុងកម្មវិធីអភិវឌ្ឍន៍ ឃុំ/សង្កាត់ ហើយក៏ដើម្បីតម្រង់ទិសដល់បុគ្គលិកមន្ទីរកិច្ចការនារីទៅលើការរៀបចំសំណើរដើម្បីស្វែងរកធនធានបន្ថែមពីខាងក្រៅសម្រាប់អនុវត្តសកម្មភាពយេនឌ័រឱ្យបានកាន់តែច្រើនទៀត។ កិច្ចប្រជុំនេះបានយល់ព្រមលើការបង្កើតសៀវភៅស្តើង និងការកំណត់ពីភាពចាំបាច់ក្នុងការពិភាក្សារកឱ្យឃើញនូវសកម្មភាពជាគន្លឹះសំខាន់ៗសម្រាប់អ្នកទទួលផលជាស្ត្រីមេគ្រួសារក្រីក្រ។ កិច្ចប្រជុំនេះបានផ្តល់អនុសាសន៍លើការចុះបំពេញបេសកកម្មនៅមូលដ្ឋានក្នុងមួយរយៈពេលខ្លី។ បេសកកម្មនេះរៀបចំនៅក្នុងភូមិគោលដៅទាំង៧ នៅក្នុងស្រុកស៊ីធរកណ្តាល និងស្រុកពាមជរ៍ ខេត្តព្រៃវែង។ ទោះបីជាតំបន់គ្របដណ្តប់របស់បេសកកម្មនេះកំណត់នៅក្នុងខេត្តព្រៃវែងក៏ដោយ ក៏មន្ទីរកិច្ចការនារីខេត្តកណ្តាលបានចូលរួមយ៉ាងសកម្មផងដែរនៅក្នុងបេសកកម្មនេះ។ សេចក្តីព្រាងចុងក្រោយរបស់សៀវភៅស្តើងនេះបានរៀបចំនៅពេលចុងបញ្ចប់នៃបេសកកម្មនេះ ដោយសេចក្តីព្រាង មិនត្រឹមតែប្រើប្រាស់នូវការរកឃើញរបស់បេសកកម្មប៉ុណ្ណោះទេ ថែមទាំងបានប្រើប្រាស់នូវលទ្ធផលជាច្រើនពីសកម្មភាពនានា ដែលទាក់ទងនឹងស្ត្រីក្រីក្រជាមេគ្រួសារផងដែរ។



*មន្ត្រីមន្ទីរ-ការិយាល័យកិច្ចការនារីខេត្ត និងស្រុក ហើយនិងអង្គការបំលាស់ប្តូរជាវិជ្ជមានសំរាប់កម្ពុជា(PCC) បានជួបប្រជុំគ្នាដើម្បីរៀបចំផែនការនិងសកម្មភាពទាក់ទងនឹងសេចក្តីត្រូវការរបស់ស្ត្រីមេគ្រួសារ។*

## មេរៀន និងបទពិសោធន៍ ដែលទទួលបានពីការអនុវត្តន៍

- មន្ទីរកិច្ចការនារី និងយុទ្ធជនខេត្ត/ស្រុក ទទួលបានបទពិសោធយ៉ាងទូលំទូលាយនៅក្នុងការអនុវត្តសកម្មភាពទាក់ទងនឹងអំពើហឹង្សា ក្នុងគ្រួសារនិងសុខភាព ប៉ុន្តែមិនមែនសកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយនោះទេ។ ប៉ុន្តែបទពិសោធន៍ និងសមត្ថភាព ដែលមានស្រាប់របស់ពួកគេ អាចជាគុណប្រយោជន៍ដ៏អស្ចារ្យនៅក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ។ ដូចនេះហើយ ការពង្រឹងសមត្ថភាពបណ្តាញកិច្ចការនារីដែលមានស្រាប់នៅគ្រប់កម្រិតអំពីការងារកាត់បន្ថយគ្រោះមហន្តរាយ គួរតែជាគោលគំនិតសំខាន់ដ៏មានអាទិភាពមួយ។
- ការរៀបចំនិងការអនុវត្តកម្មវិធីដ៏ច្រើន ដែលកំណត់យកក្រុមងាយរងគ្រោះមួយរបស់សហគមន៍ វានឹងអាចធ្វើឱ្យមានអត្ថប្រយោជន៍ថ្មីដ៏ល្អមួយ ហើយបានទទួលអត្ថប្រយោជន៍យ៉ាងច្រើនលើតម្រូវការរបស់ក្រុមនេះ។
- ការបង្កើនសមត្ថភាពអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំអាចធានាឱ្យមាននូវនិរន្តរភាពនៃគោលគំនិតកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងក៏បានជំរុញឱ្យមានការអនុវត្តបន្តជាច្រើននៅក្នុងតំបន់ដែលមានបញ្ហាដូចគ្នានេះ។
- ការសម្របសម្រួលកិច្ចសហការយ៉ាងជិតស្និទ្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនិងបណ្តាញកិច្ចការនារីដែលមានស្រាប់នៅគ្រប់កម្រិតនឹងអាចជួយពង្រឹងកិច្ចសហប្រតិបត្តិការទាំងខ្សែបណ្តោយ និងខ្សែទទឹងរវាងស្ថាប័នសមាជិកគណៈកម្មាធិការទាំងនេះ។
- ការឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក នៅក្នុងតួនាទីសម្របសម្រួលបានសាបព្រួសយ៉ាងច្រើននៅក្នុងការ រៀបចំ និងការអនុវត្តន៍កម្មវិធីថ្មីជាច្រើន និងក៏បានជួយគាំទ្រដល់សកម្មភាពបង្កើនសមត្ថភាពជាច្រើនផងដែរនៅតាមមូលដ្ឋាន។

## ជំហានបន្ទាប់

មន្ទីរនិងការិយាល័យកិច្ចការនារីខេត្ត និងស្រុករបស់ខេត្តកណ្តាលនិងខេត្តព្រៃវែង បានយល់ឃើញថាសកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ដែលផ្តោតលើស្ត្រីក្រីក្រជាមេគ្រួសារពិតជាមានតម្លៃខ្លាំងណាស់ និងទទួលស្គាល់លើការបង្កើនចំនេះដឹងមូលដ្ឋានគ្រឹះនៅថ្នាក់ឃុំតាមរយៈការកសាងសមត្ថភាពរបស់អ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ។ ប៉ុន្តែពួកគេក៏នៅតែបង្ហាញភាពមិនពេញចិត្ត ដែលមិនមានសកម្មភាពអាចចូលរួមចំណែកជួយដល់ការលំបាកក្នុងជីវភាពរស់នៅរបស់គ្រួសារក្រីក្រដែលស្ត្រីជាមេគ្រួសារ។ ពួកគេយល់ថា វគ្គបណ្តុះបណ្តាលតែមួយមុខមិនអាចធ្វើឱ្យស្ត្រីក្រីក្រទាំងនេះរស់នៅបានប្រកបដោយលក្ខណៈប្រសើរបានឡើយ។

អ្នកសម្របសម្រួលសកម្មភាពបង្កើនការយល់ដឹង មានការព្រួយបារម្ភដ៏ចាំបាច់មួយ គឺការមិនសូវមានការចូលរួមឱ្យបានច្រើនពីស្ត្រីក្រីក្រ ដែលជាមេគ្រួសារនៅក្នុងកម្មវិធីបង្កើនការយល់ដឹង។ ការចូលរួមគួរតែសម្របសម្រួលឱ្យមានច្រើននៅក្នុងការងាររៀបចំសកម្មភាពបង្កើនការយល់ដឹងនេះ ដើម្បីធ្វើឱ្យសហគមន៍ទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំសកម្មភាពចូលរួមនេះ។ ការធ្វើបែបនេះកាន់តែមានសារៈសំខាន់ ខ្លាំងឡើងដល់ស្ត្រីក្រីក្រដែលជាមេគ្រួសារ។ ប្រការដែលឱ្យពួកគេរៀបចំពេលវេលាកន្លះថ្ងៃឬរយៈពេលមួយថ្ងៃដោយមិនទទួលបានប្រាក់ចំណូល ក៏គឺជាការលំបាកមួយសម្រាប់ពួកគាត់។

ជាមួយគ្នានេះដែរ មានចំណាប់អារម្មណ៍ជាច្រើនត្រូវបានគាំទ្រដល់ការចែករំលែកព័ត៌មានលើការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ ហើយកម្លាំងជំហរនេះគួរតែរក្សាឱ្យមានជារៀងរហូត។ ដូចនេះហើយ ស្ថាប័នដឹកនាំគឺមន្ទីរកិច្ចការនារីខេត្ត និងស្រុកសង្ឃឹមថានឹងអាចប្រមូលកៀងគររកជំនួយបន្ថែមទៀត ដើម្បីអនុវត្តសកម្មភាពកាត់បន្ថយគ្រោះភ័យនៃគ្រោះទឹកជំនន់ក៏ដូចជាវគ្គបណ្តុះបណ្តាលពង្រឹងជំនាញបន្ថែម ដោយមានការគាំទ្រដោយមូលនិធិមូលដ្ឋានសម្រាប់ជួយគ្រួសារស្ត្រីក្រីក្រអាចចិញ្ចឹមជីវិតបានយ៉ាងសមរម្យគ្រប់ពេលវេលាពេញមួយឆ្នាំ។

លើសពីនេះទៀត តាមរយៈការអនុវត្តសកម្មភាពផ្តោតលើស្ត្រីក្រីក្រជាមេគ្រួសារ មន្ទីរនិងការិយាល័យកិច្ចការនារីខេត្តនិងស្រុកបានបង្កើនកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយនឹងលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុករបស់ពួកគេរៀងៗខ្លួន។ ទោះជាយ៉ាងនេះក៏ដោយ ក៏នៅតែជាបញ្ហាមួយក្នុងការធានាឱ្យមានដៃគូជាអចិន្ត្រៃយ៍មួយរវាងស្ថានប័ននានា។ នៅថ្នាក់ជាតិគេសង្កេតឃើញថា វាមិនមានកិច្ចសហប្រតិបត្តិការបានច្រើនទេ រវាងក្រសួងកិច្ចការនារី (MoWA) និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM កម្ពុជា)។

ប្រការទាំងនេះគួរតែពិចារណាថា នៅពេលខ្លះកម្មវិធីដែលផ្តោតលើបញ្ហាយេនឌ័រ បានបង្កើតឱ្យមានដោយអចេតនា នូវការយល់ច្រឡំជាច្រើន និងបានធ្វើឱ្យស្ថាប័នដៃគូនានាជាច្រើនលែងមានភាពជិតស្និទ្ធនឹងគ្នា។ ដើម្បីចៀសវាងនូវការភាន់ច្រឡំនេះ ហើយក៏ដើម្បីបំពេញនូវសេចក្តីរំពឹងនៃរចនាសម្ព័ន្ធកិច្ចការនារីក្នុងការដឹកនាំនៅក្នុងកម្មវិធីផ្តោតលើបញ្ហាយេនឌ័រនៅក្នុងប្រទេសកម្ពុជា ជាពិសេសនៅក្នុងវិស័យមួយគឺការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ដែលមានធនធានជំនួយគាំទ្រ និងការយល់ដឹងនៅមានកម្រិតរបស់សមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់កម្រិត ដែលកត្តាទាំងនេះគឺជាប្រការដ៏ចាំបាច់។ ដូចនេះរួមសេចក្តីមក ការបន្តកសាងសមត្ថភាពរបស់ស្ថាប័ន កិច្ចការនារីនៅគ្រប់កម្រិត ការលើកកម្ពស់ការយល់ដឹងរបស់ដៃគូលើការងារកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយទាំងអស់ទៅលើបញ្ហាយេនឌ័រនេះ ត្រូវតែចាត់ទុកជាសកម្មភាពដែលត្រូវតែធ្វើជាបន្តទៅទៀត ដែលទាំងនេះជាទំនួលខុសត្រូវទាំងមូលរបស់ក្រសួងកិច្ចការនារី។

## សេចក្តីថ្លែងអំណរគុណ

សហគមន៍មានសុវត្ថិភាព សូមថ្លែងអំណរគុណចំពោះការចូលរួមចំណែកពីអ្នកទាំងអស់ដូចខាងក្រោមក្នុងការរៀបចំចងក្រងករណីសិក្សានេះ :

លោក Aloysisus Rego ប្រធានក្រុម ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ
លោក Thanongdeth Insisiengmay ប្រធានគ្រប់គ្រងកម្មវិធី ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ ADPC, ប្រទេសកម្ពុជា
លោក Aslam Perwaiz ប្រធានគ្រប់គ្រងគំរោង, ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ, ប្រទេសថៃ
លោក ជុំ វុទ្ធី , ប្រធានគ្រប់គ្រងគំរោងថ្នាក់ជាតិ, ADPC, ប្រទេសកម្ពុជា
លោក អុល សែន, អ្នកសំរបសំរួលកម្មវិធី, ADPC, ប្រទេសកម្ពុជា
លោក ប៊ី ច័ន្ទតុលា, ជំនួយការគំរោង, ADPC, ប្រទេសកម្ពុជា
អ្នកស្រី Hnin Nwe Win, អ្នកនិពន្ធ
លោក លឹម តារា, អ្នករចនាអត្ថបទ

សហគមន៍មានសុវត្ថិភាព ជាឈុតនៃករណីសិក្សា ដែលបានដកស្រង់យកអនុវត្តន៍ល្អៗមកបង្ហាញទាក់ទងនឹងការត្រៀមបង្ការ និងកាត់បន្ថយ គ្រោះមហន្តរាយ ដែលបានអនុវត្តដោយរាជរដ្ឋាភិបាលនិង អង្គការក្រៅរដ្ឋាភិបាល សំដៅកាត់បន្ថយភាពងាយរងគ្រោះ និង គ្រោះភ័យនៃគ្រោះមហន្តរាយរបស់សហគមន៍ ដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយនានា ។

ករណីសិក្សានេះ មានទិសដៅផ្តល់ដល់អ្នកធ្វើការសំរេចចិត្ត អ្នកធ្វើផែនការអភិវឌ្ឍន៍ អ្នកអនុវត្តន៍ការងារគ្រប់គ្រងគ្រោះមហន្តរាយ អ្នកដឹកនាំសហគមន៍ និង អ្នកអប់រំនានានូវគំនិតច្នៃប្រឌិត ឧបករណ៍ យុទ្ធសាស្ត្រ និង ជំរើសគោលនយោបាយនានា ដែលបានដកស្រង់ពីបទពិសោធន៍ពិតប្រាកដ ការអនុវត្តន៍ល្អៗ និង មេរៀនល្អៗ ដែលទទួលបានពីតំបន់អាស៊ីប៉ាស៊ីហ្វិច ទាក់ទង នឹងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង កាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍ ព្រមទាំងកសាងអោយបាននូវភាពជួយខ្លួនឯងរបស់សហគមន៍ និង ធ្វើអោយមានសង្គម ដែលមានការត្រៀមបង្ការគ្រោះមហន្តរាយបានល្អប្រសើរ ។

ក្នុងដំណាក់កាលទី១នេះ ករណីសិក្សាមួយចំនួនត្រូវបានរៀបចំក្រោមផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយ គ្រោះទឹកជំនន់ (FMMP) របស់គណៈកម្មការទន្លេមេគង្គ ។ ដូចនេះករណីសិក្សានេះបានផ្តោតសំខាន់តែទៅលើការគ្រប់គ្រងគ្រោះភ័យនៃគ្រោះទឹកជំនន់នៅតាមតំបន់ភូមិសាស្ត្រនៃប្រទេស ជាសមាជិកគណៈកម្មការទន្លេមេគង្គ ដែលមាន ប្រទេសកម្ពុជា ឡាវ ថៃឡង់ដ៏និងវៀតណាម ។ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍និង ការអនុវត្តន៍ល្អៗដែលទទួលបាន ពីបណ្តាប្រទេសដទៃទាក់ទងនឹងគ្រោះ មហន្តរាយធម្មជាតិនឹងត្រូវដាក់បញ្ចូលបន្ថែម នៅពេលក្រោយៗទៀត ។

គោលបំណងនៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ របស់គណៈកម្មាធិការទន្លេមេគង្គ គឺដើម្បីការពារ និងកាត់បន្ថយទុក្ខវេទនារបស់ប្រជាជន និងការខូចខាតសេដ្ឋកិច្ច ដែលបណ្តាលមកពី គ្រោះទឹកជំនន់ និងថែរក្សាបរិស្ថាននៃទឹកជំនន់អោយនៅគង់វង្ស ។ កម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់មាន ៥ផ្នែកសំខាន់ៗដូចខាងក្រោម:

ផ្នែកទី ១ : បង្កើតមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់

ផ្នែកទី ២ : វិធានការណ៍បែបរចនាសម្ព័ន្ធ និងការទប់ស្កាត់គ្រោះទឹកជំនន់

ផ្នែកទី ៣ : ការសំរបសំរួលបញ្ហាគ្រោះទឹកជំនន់ឆ្លងដែន

ផ្នែកទី ៤ : ការពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់

ផ្នែកទី ៥ : ការគ្រប់គ្រងដី

ផ្នែកទី៤ "គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS)" នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ (FMMP) នេះ ត្រូវបានអនុវត្តដោយគណៈកម្មការទន្លេមេគង្គ ដោយជំនួយបច្ចេកទេស ពីមជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី និងឧបត្ថម្ភថវិកាដោយភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ប្រទេសអាឡឺម៉ង់ (GTZ) ដែលបានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០០៤ ដល់ខែមេសា ឆ្នាំ២០០៨។ តំបន់គោលដៅរបស់គំរោងនេះមាននៅក្នុងប្រទេសកម្ពុជា និងវៀតណាម ដែលប្រទេសនីមួយៗយកខេត្ត២ និងស្រុក៤ ជាតំបន់គោលដៅ ។ ដៃគូររបស់គំរោងនេះ មានគណៈកម្មាធិការជាតិទន្លេមេគង្គ, គណៈ កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអាជ្ញាធរមូលដ្ឋានប្រចាំខេត្ត ស្រុក និងឃុំរបស់គេ, មន្ទីរ-ការិយាល័យពាក់ព័ន្ធ, ស្ថាប័នផ្សេងៗ, កាកបាទក្រហម, អង្គការអន្តរជាតិ, អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ, ។ល ។

ចាប់តាំងពីឆ្នាំ ២០០៤ មក គំរោងពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ (FEMS) បានសំរេចសមិទ្ធិផលដូចខាងក្រោម:

១-កម្មវិធិត្រៀមបង្ការគ្រោះទឹកជំនន់ នៅក្នុងស្រុកនិងខេត្តគោលដៅត្រូវបានបង្កើត និងអនុវត្ត

២-សមត្ថភាពថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិត្រូវបានបង្កើនក្នុងការគាំទ្រទៅលើដំណើរការបង្កើត និងអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ តាមរយៈការបណ្តុះបណ្តាលនៅកំរិតមូលដ្ឋាន ស្តីការគ្រប់គ្រង គ្រោះទឹកជំនន់នៅតាមសហគមន៍, ការប៉ាន់ប្រមាណការខូចខាតនិងសេចក្តីត្រូវការ, ការរុករកនិងសង្គ្រោះ, ការគ្រប់គ្រងគ្រោះអាសន្នដល់កុមារតូចៗ, ការបង្ហាត់ហែលទឹកដល់កុមារ ។ល ។ ហើយនិងការចូលរួម ទៅក្នុងការអនុវត្តគំរោង ។

៣-ការផ្សព្វផ្សាយយល់ដឹងជាសាធារណៈស្តីពីវិធានការសុវត្ថិភាពគ្រួសារថ្នាក់មូលដ្ឋានត្រូវបានបង្ហាញ រួមមានការផ្សព្វផ្សាយដល់គ្រូបង្រៀន និងកម្មវិធីសុវត្ថិភាពគ្រោះទឹកជំនន់នៅតាមសាលារៀន, ការកំណត់ពីតំរូវការចាំបាច់របស់ស្ត្រីមេគ្រួសារ, ការសំដែងសិល្បៈ, ចាប៉ីដងវែង, ការចែកផ្សព្វផ្សាយសៀវភៅទឹកជំនន់, ផ្ទាំងរូបភាព ជាដើម ។

៤-ការចែករំលែកបទពិសោធន៍ថ្នាក់មូលដ្ឋាន និងតំបន់ត្រូវបានរៀបចំឡើងតាមរយៈសិក្ខាសាលាជាតិ និងតំបន់ ព្រមទាំងធ្វើការបែងចែកឯកសារបទពិសោធន៍ល្អៗជាច្រើន ។

---

**សំរាប់ពត៌មានបន្ថែម អ្នកអានអាចទាក់ទងអាស័យដ្ឋានដូចខាងក្រោម**


អ្នកសំរបសំរួលកម្មវិធីគ្រប់ គ្រងនិងកាតបន្ថយគ្រោះទឹកជំនន់
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.mrcmekong.org

ប្រធានគ្រប់គ្រងកម្មវិធី, មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី
មជ្ឈមណ្ឌលគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ប្រចាំតំបន់,
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អាគារលេខ ៥៧៦, ផ្លូវជាតិលេខ២, សង្កាត់ចាក់អង្រែក្រោម, ខ័ណ្ឌមានជ័យ, រាជធានីភ្នំពេញ
គេហទំព័រ : www.adpc.net email : antonio@adpc.net


---

**ដៃគូរគំរោង**


លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC)
ប្រអប់សំបុត្រលេខ ៦១០១ អគារលេខ ១៨ បានស៊ីថានេនូវ ខ័ណ្ឌស៊ីកុតថាបុង
ក្រុងវៀងច័ន្ទ ប្រទេសឡាវ
ទូរស័ព្ទ: (៨៥៦) ២១ ២៦៣ ២៦៣ ទូរសារ: (៨៥៦) ២១ ២៦៣ ២៦៤
អ៊ីម៉ែល: mrcs@mrcmekong.org វ៉ិបសាយ: http://www.mrcmekong.org

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC)
ផ្ទះលេខ ២៣ មហាវិថីម៉ៅសេទុង ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ: (៨៥៥) (២៣) ២១៨ ៧២៧ ទូរសារ: (៨៥៥) (២៣) ២១៨ ៥០៦
អ៊ីម៉ែល: cnmcs@cnmc.gov.kh វ៉ិបសាយ: http://www.camnet.com.kh/cnmcs

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)
ផ្លូវលេខ ៥១៦ សង្កាត់ទួលសង្កែ ខ័ណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ/ ទូរសារ: (៨៥៥) (២៣) ៨៨២ ០៤៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តកណ្តាល (PCDM)
ឃុំដើមមាន ស្រុកតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៤២៥៥៥៥

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្តព្រៃវែង (PCDM)
ឃុំកំពង់លាវ ស្រុកកំពង់លាវ ខេត្តព្រៃវែង ប្រទេសកម្ពុជា
ទូរសារ: (៨៥៥) (២៣) ៩៤៤ ៥៤៦

adpc

មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)
SM Tower, ជាន់ ទី២៤, ៩៧៩/៦៩, Paholyothin, Samsen Nai, Phayathai,
ក្រុងបាងកក, ប្រទេសថៃ
ទូរស័ព្ទ: (៦៦) ២២ ៩៨ ០៦៨១ ដល់ ៩២
ទូរសារ: (៦៦) ២២ ៩៨ ០០១២ ដល់ ១៣
អ៊ីម៉ែល: adpc@adpc.net វ៉ិបសាយ: www.adpc.net



ឧបត្ថម្ភដោយ:

gtz Partner for the Future Worldwide
on behalf of:
Federal Ministry for Economic Cooperation and Development

ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស ប្រទេសអាឡឺម៉ង់ (GTZ)